NILP *Peer2Peer Resources for People with Disabilities*

NORTHEAST INDEPENDENT LIVING PROGRAM INC.

## ការងារប្រចាំថ្ងៃរបស់យើងត្រូវបានត្រួសត្រាយផ្លូវដោយ **ចក្ខុវិស័យរបស់យើង៖**

កម្មវិធី Northeast Independent Living Program ត្រូវបានគេស្គាល់ទូទាំងរដ្ឋ ក្នុងការជួយដល់មនុស្សជាច្រើនអោយទទួលបាន និង រក្សាឯករាជ្យភាព និង សមភាពរបស់ពួកគេនៅក្នុងសហគមន៍ តាមរយៈការផ្តល់ព័ត៌មាន និងការណែនាំបញ្ជូនបន្ត, ការតស៊ូមតិ, ការបណ្តុះបណ្តាលជំនាញ, ការផ្តល់ការប្រឹក្សាពីបុគ្គលដែលមាន

ស្ថានភាពប្រហាក់ប្រហែលគ្នា និង ការផ្តល់សេវាដើម្បីការផ្លាស់ប្តូរពីស្ថានភាពមួយទៅកាន់ស្ថានភាពមួយទៀត។ យើងជាសហគមន៍ពលរដ្ឋដែលបើកទ្វារផ្តល់ឱកាស ដើម្បីសហគមន៍មួយសម្រាប់មនុស្សគ្រប់ស្រទាប់វណ្ណៈដែលមិនមានឧបសគ្គឡើយក្នុងការទំនាក់ទំនងគ្នា, ឥរិយាបទខុសគ្នា, ស្ថានភាពសេដ្ឋកិច្ចខុសគ្នា, និង ឧបសគ្គទាក់ទងនឹងសំណង់អគារសម្រាប់មនុស្សដែលមានពិការភាពទាំងអស់។

## តើអ្នកដឹងទេ?

**NILP ផ្តល់ជូននូវកម្មវិធីជាច្រើនដល់សហគមន៍ដែលយើងផ្តល់សេវាកម្ម។** កម្មវិធីរបស់យើង អាចដាក់រួមបញ្ចូលគ្នាដើម្បីផ្តល់ជូននូវសេវាកម្មដ៏ល្អបំផុតជាច្រើនដែលយើងអាចធ្វើទៅបាន។ សេវាកម្មរបស់យើងមិនមានការគិតថ្លៃនោះទេ លើកលែងតែសេវាកម្មផ្នែកអប់រំរបស់យើង។

- សេវាគាំទ្រសហគមន៍
- ការផ្តល់ជំនួយ និងសេវាកម្មរយៈពេលវែង
- សេវាជួយផ្លាស់ទៅរស់នៅកន្លែងមើលថែមនុស្សចាស់
- កម្មវិធីជំនួយផ្តល់អ្នកមើលថែទាំផ្ទាល់ខ្លួន
- គំរោងផ្តល់ធនធានទាក់ទងនឹងពិការភាព និងជរាភាពរបស់ Merrimack Valley— ការផ្តល់ប្រឹក្សាអំពីជម្រើសផ្សេងៗដល់ជនពិការ និងគ្រួសាររបស់ពួកគេ
- កម្មវិធីសេវាយុវជន
- ផ្នែកសេវាអប់រំ



## សូមទាក់ទងមកពួកយើង!

www.nilp.org/NERLC

www.facebook.com/NERLC

ឈ្មោះ៖ ______________________

ទូរស័ព្ទ៖ ______________________



# លោកអ្នកមិនឯកាទេ។

The Northeast Recovery Learning Community

កម្មវិធីរបស់ Northeast Independent Living Program

# តើកម្មវិធី NERLC របស់យើងគឺជាអ្វី?

The Northeast Recovery Learning Community (NERLC) ផ្តល់ទីកន្លែងដែលមានភាពស្វាគមន៍រាក់ទាក់, មានសុវត្ថិភាព, មានការយោគយល់, និង មិនមានការវិនិច្ឆ័យណាមួយដែលបុគ្គលគ្រប់ស្រទាប់វណ្ណៈអាចមកប្រមូលផ្តុំដើម្បីទទួលការព្យាបាលសុខភាព និង ភាពរីកចម្រើន។

## យើងខ្ញុំជាសហគមន៍នៃក្រុមបុគ្គលដែលស្ថិតក្នុងការព្យាបាលបញ្ហាសុខភាពផ្លូវចិត្តការញៀនថ្នាំ និង/ឬបទពិសោធន៍ជីវិតដែលមានវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ។

NERLC ផ្តល់ការគាំទ្រដល់បុគ្គលគ្រប់រូបក្នុងដំណើរឆ្ពោះទៅរកការទទួល និងការថែរក្សាបាននូវសុខភាពល្អ ហើយយើងខិតខំធ្វើការដើម្បីផ្សារភ្ជាប់សមាជិករបស់យើងជាមួយនឹងសហគមន៍ដែលពួកគេរស់នៅ។ យើងផ្តល់សេវាកម្មនៅក្នុងទីក្រុងធំៗ និងទីក្រុងតូចៗចំនួន 69 នៅតំបន់ភាគឦសាននៃសហរដ្ឋអាមេរិក។



# តើសេវាគាំទ្រអ្នកដែលមានស្ថានភាពដូចគ្នា ជាសេវាកម្មអ្វី?

*“សេវាគាំទ្រអ្នកដែលមានស្ថានភាពដូចគ្នាជាដំណើរការនៃការផ្តល់ និង ទទួលការលើកទឹកចិត្តនិងជំនួយពីគ្នាទៅវិញទៅមកដើម្បីសម្រេចបានការជាសះស្បើយរយៈពេលវែង។*

*អ្នកគាំទ្រម្នាក់ៗផ្តល់នូវការគាំទ្រផ្នែកអារម្មណ៍, ចែករំលែកចំណេះដឹង, បង្រៀនជំនាញ, ផ្តល់ជំនួយជាក់ស្តែង, និងទំនាក់ទំនងមនុស្សផ្សេងៗជាមួយនឹងធនធាន, ឱកាស, សហគមន៍ដែលផ្តល់ជំនួយអោយគ្នាទៅវិញទៅមក, និងមនុស្សដទៃទៀត។”*

(Mead, 2003; Solomon, 2004)



អ្នកឯកទេស និង គ្រូបង្វឹកជួយអោយជាសះស្បើយឡើងវិញរបស់ NERLC គឺជាអ្នកឯកទេស និង គ្រូដែលមានវិញ្ញាបនបត្របញ្ជាក់ពីរដ្ឋ ហើយប្រើប្រាស់បទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេទាក់ទងនឹងសុខភាពផ្លូវចិត្ត, ការញៀនថ្នាំ, និង ការជាសះឡើងវិញពីភាពប៉ះទង្គិចខ្លាំង ដើម្បីធ្វើការផ្តល់ការគាំទ្រដែលផ្តោតទៅលើការតស៊ូមតិ, ការអប់រំ, ការណែនាំចង្អុលបង្ហាញ, និងការលើកទឹកចិត្ត។

The Northeast Recovery Learning Community

## NERLC ផ្តល់ជូន៖

- សេវាទទួលការគាំទ្រមួយទល់នឹងមួយពីបុគ្គលដែលមានស្ថានភាពដូចលោកអ្នក
- សេវាទទួលការគាំទ្រជាក្រុម
- សិក្ខាសាលា និងការបណ្តុះបណ្តាល
- សេវាផ្តល់ជំនួយដល់គ្នាទៅវិញទៅមកដើម្បីត្រៀមចេញទៅធ្វើការងារ
- កម្មវិធីសង្គមផ្សេងៗ
- កម្មវិធីជាក្រុម និងសកម្មភាពផ្សេងៗសម្រាប់មនុស្សវ័យជំទង់ (18+) រហូតដល់មនុស្សចាស់
- សេវាក្រុមគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នា LGBTQIA+
- សេវាក្រុមគាំទ្រអ្នកដែលជាសះស្បើយពីការញៀនថ្នាំ
- ការផ្តល់ព័ត៌មាន និងការណែនាំបញ្ជូនបន្ត
- ការតស៊ូមតិ

## សូមមកជួបជាមួយពួកយើង

### សូមធ្វើការណាត់ជួបនៅការិយាល័យកណ្តាលរបស់យើងណាមួយ៖

NILP

**Lawrence (ទីក្រុងឡូរិន)**
20 Ballard Road, Lawrence, MA 01843
978-687-4288 តំណរភ្ជាប់ 131

**Lynn (ទីក្រុងលីន)**
1 Market Street, Ste 203, Lynn, MA 01901
978-687-4288 តំណរភ្ជាប់ 202